# កំណត់ហេតុ

## កិច្ចប្រជុំពិសេសរវាងប្រធានគណៈកម្មការចម្រុះ

## ខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម វៀតណាម-កម្ពុជា

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០៧

*****

កិច្ចប្រជុំរវាងប្រធានគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម វៀតណាម-កម្ពុជា បានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០៧ នៅរាជធានីភ្នំពេញ ។ គណៈប្រតិភូ នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម ។ គណៈប្រតិភូរដ្ឋាភិបាលវៀតណាមដឹកនាំដោយឯកឧត្តម **វូ យុង** អនុរដ្ឋមន្ត្រី ក្រសួងការបរទេស និងជាប្រធានគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកវៀតណាម-កម្ពុជា ។

បញ្ជីរាយនាមសមាសភាពគណៈប្រតិភូកម្ពុជា និងគណៈប្រតិភូវៀតណាម មានចែងក្នុងឧបសម្ព័ន្ធ ក និង ខ នៃកំណត់ហេតុនេះ ។

នៅក្នុងឱកាសស្នាក់នៅទីក្រុងភ្នំពេញ នាថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៧ **ឯកឧត្តម វូ យុង** និងគណៈប្រតិភូព្រំដែនវៀតណាម បានចូលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាព ស្មោះត្រង់ និងយោគយល់គ្នា ទៅវិញទៅមក ។ ភាគីទាំងពីរបានឯកភាពគ្នាលើចំណុចមួយចំនួនដូចខាងក្រោម :

១-ភាគីទាំងពីរប្តេជ្ញាធ្វើការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកឱ្យបានមុនបំណាច់ឆ្នាំ ២០០៨ និងវាយតម្លៃលទ្ធផលការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ក្នុងឆ្នាំ២០០៦ និងអនុម័តផែនការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ឆ្នាំ២០០៧ ។

២-ភាគីទាំងពីរបានពិនិត្យ និងអនុម័តយក :

ក-កំណត់ហេតុកិច្ចប្រជុំក្រុមជំនាញលើកទី៤ នៃគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោល

ព្រំដែនគោកកម្ពុជា-វៀតណាម ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៧ (ឧបសម្ព័ន្ធទី១)

ខ-កំណត់ហេតុកិច្ចប្រជុំអនុគណៈកម្មការបច្ចេកទេសចម្រុះលើកទី២ នៃគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧ (ឧបសម្ព័ន្ធទី២) ។

៣-ស្តីពីការផលិតផែនទីឯានលេខាថ្មីនៅតំបន់ព្រំដែនកម្ពុជា-វៀតណាម នៅក្នុងចំណុច គ នៃកំណត់ហេតុកិច្ចប្រជុំលើកទី២ នៃអនុគណៈបច្ចេកទេសចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម នៅរាជធានីភ្នំពេញ នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ភាគីទាំងពីរយល់ឃើញថា មិនគួរលើកឡើងនាពេលនេះទេ ហើយសម្រេចទុកបញ្ហានេះពិភាក្សាគ្នានៅពេលក្រោយ ។

៤-ដើម្បីឱ្យដំណើរការខណ្ឌសីមា និងបោះបង្គោលព្រំដែន លើដីជាក់ស្តែងបានបញ្ចប់តាមការគ្រោងទុកនាឆ្នាំ ២០០៨ ភាគីកម្ពុជាស្នើឱ្យភាគីវៀតណាមផ្តល់ទូរផែនទី UTM ខ្នាត ១/៥០.០០០ ដែលគ្មានខ្សែព្រំដែនចំនួន ០៦ ច្បាប់បន្ថែមទៀតដើម្បីគូសចម្លងខ្សែព្រំដែន ។ ភាគីវៀតណាមទទួលយកសំណើនេះ ហើយនឹងប្រគល់ជូនភាគីកម្ពុជានៅពេលក្រោយ ។

៥-ស្តីពីផែនការខណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនឆ្នាំ ២០០៧ :

ក-ភាគីកម្ពុជាសម្រេចបង្កើនចំនួនក្រុម ខ.ស.ប.ប.គ ពី ០២ក្រុមទៅ ០៣ ក្រុម ។ ភាគីវៀតណាម ត្រៀមជាស្រេចជួយបណ្តុះបណ្តាលអ្នកបច្ចេកទេសលើដីជាក់ស្តែង ។ ភាគីកម្ពុជានឹងជូនដំណឹងទៅភាគីវៀតណាមឱ្យបានឆាប់ដែលអាចធ្វើទៅបាន ស្តីពីការបណ្តុះបណ្តាលនេះ ។

ខ-បង្កើតក្រុមការងារផ្នែកការិយាល័យមួយ ទទួលភារកិច្ចផ្ទៀងផ្ទាត់ការគូសចម្លងខ្សែព្រំដែនជាទ្វេភាគី ពីផែនទី Bonne ខ្នាត ១/១០០.០០០ មកលើផែនទី UTM ខ្នាត ១/៥០.០០០ អមសន្ធិសញ្ញាឆ្នាំ ១៩៨៥ ដែលនឹងត្រូវចាប់ផ្តើមការងាររបស់ខ្លួនពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧ ហើយការងារនេះនឹងត្រូវបញ្ចប់ ក្នុងខែ ឧសភា ឆ្នាំ ២០០៧ ព្រមទាំងរាយការណ៍ជូនប្រធាន គណៈកម្មការចំរុះដើម្បីពិនិត្យ និងសម្រេច ។

គ-ចាប់ពីខែ ឧសភា ឆ្នាំ ២០០៧ ភាគីទាំងពីរអនុវត្តការងារ ខ.ស.ប.ប.គ ពីទិសខាងជើងទៅទិសខាងត្បូង ហើយធ្វើការបោះបង្គោលព្រំដែននៅកន្លែងណាដែលមានផ្លូវគមនាគមន៍ និងនៅតាមបណ្តាច្រកទ្វារព្រំដែន ដើម្បីបំរើការងារអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ក្នុងឆ្នាំ ២០០៧ នេះ ភាគីទាំងពីរគ្រោងនឹងបោះបង្គោលព្រំដែនប្រមាណ មួយរយ (១០០) បង្គោល ។

ឃ-ភាគីទាំងពីរឯកភាព បញ្ចប់ការសាងសង់បង្គោលព្រំដែនលេខ ៣១៣ នៅមាត់ច្រកទ្វារ លោក(កំពត)-សាស្សៀ (គៀនយ៉ាង) និងបង្គោលលេខ ៦៩ នៅច្រកទ្វារត្រពាំងស្រែ (ស្នួល-ក្រចេះ)-បូនួរ(ប៊ិញភឿក) ត្រពាំងផ្លុង (កំពង់ចាម)-សាម៉ាត (តៃនិញ) ក្នុងខែ ឧសភា ឆ្នាំ ២០០៧ ។

ង-ភាគីទាំងពីរនឹងសម្រេចនៅចុងខែ មិថុនា ឆ្នាំ ២០០៧ នូវការសាងសង់បង្គោលព្រំដែននៅច្រកទ្វារទាំង ០២ គឺ :

-អណ្តូងពេជ្រ (រតនគិរី) -លេថាញ់ (យ៉ាឡាយ)

-ភ្នំដិន (តាកែវ)-ទិញបៀន (អានយ៉ាង) ។

ច-ភាគីទាំងពីរឯកភាពចាប់ពីខែ ឧសភា ឆ្នាំ ២០០៧ ចុះទៅពិនិត្យ និងកំណត់ទីតាំងបង្គោលជាទ្វេភាគី នៅច្រកទ្វារក្អមសំណ (កណ្តាល ) កោះរកា (ព្រៃវែង)-វិញស៊ឿង(អានយ៉ាង) ធឿងភឿក (ដុងថាប់) និងធ្វើការសាងសង់ ក្រោយពេលកំណត់ទីតាំងបង្គោលទាំងពីរនេះរួច ។

៦-ភាគីទាំងពីរឯកភាពគ្នានឹងធ្វើការពិភាក្សាជាមួយភាគីឡាវ ដើម្បីរៀបចំឱ្យមានកិច្ចប្រជុំថ្នាក់បច្ចេកទេសព្រំដែននៃប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ អំពីទីតាំងនៅចំណុចប្រសព្វបីប្រទេសនៅចុង ខែ ឧសភា ឆ្នាំ ២០០៧ នៅវៀតណាម ។

៧-ភាគីទាំងពីរឯកភាពគ្នានឹងបើកកិច្ចប្រជុំក្រុមជំនាញលើកទី៥ នៃគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម វៀតណាម-កម្ពុជា នាខែឧសភា ឆ្នាំ២០០៧ នៅទីក្រុងភ្នំពេញ ដើម្បីបញ្ចប់ការគូសចម្លងខ្សែព្រំដែន និងការងារបច្ចេកទេសមួយចំនួនទៀត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៧ ជាពីរច្បាប់ ជាភាសាខ្មែរ និងភាសាវៀតណាម ។ អត្ថបទទាំងពីរច្បាប់នេះ មានតម្លៃស្មើគ្នា ។

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះ
បង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
ប្រធាន



វ៉ា គឹមហុង

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះ
បង្គោលព្រំដែនគោកវៀតណាម-កម្ពុជា
ប្រធាន



ទូ យុង